អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ០៨៥ ស.ស.៣.១៧/អអក

ភ្នំពេញ, ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោក សាន កេ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ០៩៨ អ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ ឲ្យលោក សាន កេ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងអាណត្តិមុនគឺ ០៧ឆ្នាំ ។ ដើម្បីជួយសម្រួលអ្នកកាន់អាជ្ញាបណ្ណក្នុងការខ្ចីទុនពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងពីប្រភពហិរញ្ញវត្ថុនានា សម្រាប់ការពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅកាន់តំបន់ដែលពុំមានអគ្គិសនីប្រើប្រាស់នៅក្នុងតំបន់អាជ្ញាបណ្ណរបស់ខ្លួន និងយោងតាមការវាយតម្លៃលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណលោក សាន កេ ដោយបន្ថែមអាណត្តិអាជ្ញាបណ្ណពី ០៧(ប្រាំពីរ)ឆ្នាំ ទៅ ១២(ដប់ពីរ)ឆ្នាំ ដូចមានខ្លឹមសារជូនភ្ជាប់ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារនៃសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្តល់ជូនលោក សាន កេ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ .................... ..........................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬ ផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោក សាន កេ អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ ហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី៧
## លើឯកសារអាជ្ញាបណ្ណលេខ ០៩៨ ឯអ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ សម្រាប់លោក សាន កេ ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## សម្រាប់ការបន្ថែមអាណត្តិអាជ្ញាបណ្ណ

(ក្នុងគោលបំណងជួយសម្រួលការខ្ចីឥណទានពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ "ម.អ.ជ" ដើម្បីពង្រីកបណ្តាញទៅតំបន់ពុំទាន់មានអគ្គិសនី)

## DECISION ON THE SEVENTH REVISION

OF THE LICENSE DOCUMENT No. 098 LD DATED SEPTEMBER 15, 2004

FOR MR. SAN KE FOR PROVIDING ELECTRIC POWER SERVICE AT SOME

PART OF KHUM REAM, PREY NOB DISTRICT, PREAH SIHANOUK PROVINCE

## FOR EXTENDING THE TERM OF LICENSE

**(To facilitate to get the funds from Rural Electrification Fund "REF" for extending the electric supply to non-electrified areas)**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧

.. .., 2017